**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**និយ័តករធានារ៉ាប់រងកម្ពុជា**

ថ្ងៃសុក្រ ៨កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
សៀមរាប ថ្ងៃទី២៨ ខែវិច្ឆិកា គ.ស.២០២៥

# សេចក្តីប្រកាសព័ត៌មាន
## កិច្ចប្រជុំនិយ័តករធានារ៉ាប់រងអាស៊ាន លើកទី ២៨
## កិច្ចប្រជុំក្រុមប្រឹក្សាធានារ៉ាប់រងអាស៊ាន លើកទី៥១ និងកិច្ចប្រជុំពាក់ព័ន្ធ

កិច្ចប្រជុំនិយ័តករធានារ៉ាប់រងអាស៊ាន លើកទី២៨ (28th AIRM) កិច្ចប្រជុំក្រុមប្រឹក្សាធានារ៉ាប់រងអាស៊ាន លើកទី៥១ (51st AIC) និងកិច្ចប្រជុំពាក់ព័ន្ធបានប្រព្រឹត្តទៅកាលពីថ្ងៃទី២៥-២៨ ខែវិច្ឆិកា គ.ស.២០២៥ នៅខេត្តសៀមរាប ប្រទេសកម្ពុជា ក្រោមមូលបទ "**ការជំរុញកំណើន និងភាពធន់រួមដើម្បីជំនះបញ្ហាប្រឈមដែលកំពុងកើតមាន**"។ កម្មវិធីបើកបានប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារនៃកម្ពុជា តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារនៃកម្ពុជា។

**ឯកឧត្តម រស់ សីលវ៉ា** បានគូសរំលេចពីតម្រូវការនៃកិច្ចសហប្រតិបត្តិការក្នុងតំបន់ដ៏រឹងមាំ និងការរៀបចំបទប្បញ្ញត្តិ ដើម្បីអភិវឌ្ឍវិស័យធានារ៉ាប់រងអាស៊ានប្រកបដោយភាពធន់ បរិយាបន្ន និងនវានុវត្តន៍។ ឯកឧត្តមបានបញ្ជាក់ថា សកម្មភាពរួមមានសារៈសំខាន់ក្នុងការដោះស្រាយបញ្ហាប្រឈមដែលកំពុងកើតមាន ដូចជា ហានិភ័យអាកាសធាតុ ការវិវត្តនៃប្រព័ន្ធបច្ចេកវិទ្យា និងភាពមិនប្រាកដប្រជាជាសកល ព្រមទាំងធានាការរីកចម្រើនប្រកបដោយចីរភាព និងលើកកម្ពស់ការគាំពារជូនប្រជាជនអាស៊ាន។

កិច្ចប្រជុំនិយ័តករធានារ៉ាប់រងអាស៊ានលើកទី២៨ ជាវេទិកាប្រចាំឆ្នាំរវាងនិយ័តករធានារ៉ាប់រងពីបណ្តារដ្ឋសមាជិកអាស៊ានទាំងអស់ ដើម្បីពិភាក្សាលើរបៀបវារៈសំខាន់ៗ ដូចជា៖ ផែនការយុទ្ធសាស្ត្រសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) ឆ្នាំ២០២៦-២០៣០ ហិរញ្ញប្បទានហានិភ័យគ្រោះមហន្តរាយអាស៊ាននិងធានារ៉ាប់រង វត្តិករសាស្ត្រអាស៊ាន៖ ហិរញ្ញវត្ថុប្រកបដោយចីរភាព កិច្ចសហប្រតិបត្តិការធានារ៉ាប់រងអាស៊ាន និងការអនុវត្តពិធីសារទី៥ របស់អាស៊ានស្តីពីកាតព្វកិច្ចធានារ៉ាប់រងយានយន្ត។ កិច្ចប្រជុំបានសម្រេចលើ៖ ១).ការពិនិត្យលើផែនការសកម្មភាពរបស់ AIRM ឆ្នាំ ២០២៦-២០៣០ ដែលស្ថិតក្រោមផែនការយុទ្ធសាស្ត្រសហគមន៍សេដ្ឋកិច្ចអាស៊ាន ២).ការស្នើឱ្យមានគោលការណ៍ណែនាំជាក់លាក់ស្តីពីវត្តិករសាស្ត្រអាស៊ានសម្រាប់វិស័យធានារ៉ាប់រង និងការកសាងសមត្ថភាពសម្រាប់និយ័តករធានារ៉ាប់រងនិងភាគីពាក់ព័ន្ធក្នុងវិស័យឯកជន និង ៣).ការដាក់បញ្ចូលបច្ចេកវិទ្យា និងបរិយាបន្នក្នុងរបៀបវារៈនៃកិច្ចសហប្រតិបត្តិការធានារ៉ាប់រងអាស៊ាន។

កិច្ចប្រជុំ 51st AIC ដើរតួនាទីជាវេទិកាយ៉ាងសំខាន់សម្រាប់វិស័យឯកជនពីបណ្តារដ្ឋសមាជិកអាស៊ានទាំងអស់ ដើម្បីជួបពិភាក្សា ផ្លាស់ប្តូរការយល់ដឹង ចែករំលែកបទពិសោធន៍លើបញ្ហាប្រឈមពាក់ព័ន្ធនឹងធានារ៉ាប់រង និងលើកយកបញ្ហារួមជម្រាបជូននិយ័តករអាស៊ាន ក្នុងកិច្ចប្រជុំពេញអង្គរវាងនិយ័តករធានារ៉ាប់រងអាស៊ាននិងក្រុមប្រឹក្សាធានារ៉ាប់រងអាស៊ាន។ ជាក់ស្តែង ក្រុមប្រឹក្សាធានារ៉ាប់រងអាស៊ានបានរាយការណ៍ជូននិយ័តករ អំពីវឌ្ឍនភាពការងារនៃគណៈកម្មាធិការក្រោមឱវាទក្រុមប្រឹក្សា និងគូសរំលេចបញ្ហាមួយចំនួនសម្រាប់វិស័យធានារ៉ាប់រងទាំងអាយុជីវិត និងទូទៅ។

ជាចុងក្រោយ និយ័តករធានារ៉ាប់រងអាស៊ាន និងវិស័យឯកជន បានឯកភាពលើលទ្ធផលនៃកិច្ចប្រជុំ និងវាយតម្លៃខ្ពស់លើកិច្ចសន្ទនាជាមួយនឹងការប្តេជ្ញាដ៏មុតមាំឆ្ពោះទៅកសាងវិស័យធានារ៉ាប់រងអាស៊ានប្រកបដោយភាពធន់ បរិយាបន្ន និងនវានុវត្តន៍។